អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១១ ចេញផ្សាយ ខែវិច្ឆិកា ឆ្នាំ២០២២

# ការត្រួតពិនិត្យផ្ទៃក្នុង




អ្វីទៅជាការត្រួតពិនិត្យផ្ទៃក្នុង ?

ការត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការដែលរៀបចំ និងបង្កើតឡើងដោយថ្នាក់ដឹកនាំស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ដើម្បីផ្តល់នូវការធានាអំពីប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃកិច្ចប្រតិបត្តិការ ភាពទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ និងភាពសមស្របតាមបណ្តាច្បាប់ បទបញ្ញា គោលនយោបាយ នីតិវិធី និងការចាត់ចែងដែលត្រូវអនុវត្ត។




គោលបំណងនៃការត្រួតពិនិត្យផ្ទៃក្នុង គឺដើម្បីធានាឱ្យបាននូវគោលដៅ ឬលក្ខខណ្ឌដែលអាចកាត់បន្ថយដល់កម្រិតអប្បបរមាលើការខ្វះខាត ការបាត់បង់ ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬការបែងចែកមិនសមស្រប។ ម្យ៉ាងវិញទៀតដើម្បីឱ្យគោលបំណងនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រេចបានប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព សកម្មភាពអនុលោមតាមគោលបំណងត្រូវតែអាចវាស់វែង និងសង្កេតបាន។



ការតាមដានការត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការនៃការវាយតម្លៃដោយមន្ត្រីទទួលបន្ទុកលើការរៀបចំ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ក្នុងពេលវេលាសមស្រប និងចាត់វិធានការចាំបាច់។ ការតាមដានការត្រួតពិនិត្យផ្ទៃក្នុងអាចអនុវត្តបានតាមពីររបៀប÷

- ទី១. សកម្មភាពជាប្រចាំ÷ សំដៅដល់សកម្មភាពតាមដានប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃប្រតិបត្តិការជាធម្មតាដែលរួមមានការត្រួតពិនិត្យ និងគ្រប់គ្រងទៀងទាត់ដោយថ្នាក់ដឹកនាំ ការប្រៀបធៀប ការផ្ទៀងផ្ទាត់ និងសកម្មភាពជាប្រចាំផ្សេងៗទៀត។

- ទី២. ការវាយតម្លៃដោយឡែក÷ សំដៅដល់ការវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដោយថ្នាក់ដឹកនាំ និងឬ


ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

ដោយសវនកម្មផ្ទៃក្នុង។ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងទាក់ទងនឹងហានិភ័យកម្រិតខ្ពស់ និងសំខាន់ត្រូវវាយតម្លៃឱ្យបានញឹកញាប់។

យោងតាមក្របខ័ណ្ឌសវនកម្មកំណត់ដោយគណៈកម្មាធិការគាំទ្ររបស់ស្ទងការទ្រីដវេ (COSO) ដើម្បីវាយតម្លៃលើភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងគឺត្រូវមានផ្នែកចំនួន ៥ សំខាន់ៗ រួមមាន÷ បរិស្ថានត្រួតពិនិត្យ ការវាយតម្លៃហានិភ័យ សកម្មភាពត្រួតពិនិត្យ ព័ត៌មាន និងគមនាគមន៍ និងការតាមដាន។




ជាទូទៅ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលល្អគួររួមបញ្ចូលនូវលក្ខណៈដូចខាងក្រោម÷

- ការបែងចែកភារកិច្ចបានសមស្រប
- ការត្រួតពិនិត្យលើការគ្រប់គ្រង
- ដំហានដំណើរការមានលំដាប់លំដោយត្រឹមត្រូវ
- ការងារបាននិងកំពុងធ្វើនៅតាមទីកន្លែង និងពេលវេលាដែលត្រឹមត្រូវតាមលំដាប់លំដោយ និងជំនាញ
- ចំណុចរួមនៃការទទួលខុសត្រូវរបស់ថ្នាក់គ្រប់គ្រងត្រូវបានកំណត់
- ចំណុចដោះស្រាយ និងពាក់ព័ន្ធមានតិចបំផុត
- លំហូរការងារត្រលប់ក្រោយមានតិចបំផុត
- សកម្មភាពជាយថាហេតុមានតិចបំផុត។



*អត្ថបទ÷ លោក **ភាន់ សុភាក់***

***ឯកសារយោង÷***


*១-ការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន អគ្គនាយដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*២-អាជ្ញាធរសវនកម្មជាតិ ស្តង់ដាសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា*
*៣-COSO Internal Control-Integrated Framework*




ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។